# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


២៤-៥-២០១០ -ព្រះរាជក្រម នស/រកម/០៥១០/០០៦ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ស្តីពី ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជន នៃអគារសហកម្មសិទ្ធិដល់ជនបរទេស ៤១៣០


### ២-ព្រះរាជក្រឹត្យ


២៤-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤១១ ស្តីពី ការបន្ថយរយៈពេលទទួលរងទោសឱ្យទណ្ឌិត ចំនួន ១៨១ នាក់ និង លើកលែងទោសឱ្យទណ្ឌិតចំនួន ៤៣ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស ក្នុងពន្ធនាគារកន្លងមក ៤១៤២

២៤-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤១២ ស្តីពី ការប្រោសព្រះរាជទាន ចំពោះ សព លោក ហ៊ុន ស៊ីលីន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ជាកិច្ចបច្ឆាមរណៈ ៤១៦៥

២៤-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤១៣ ស្តីពី ការតែងតាំងឯកឧត្តម **សំអឿន គីមហឿន** ជា សមាជិកទី ២ នៃអាជ្ញាធរអគ្គិសនីកម្ពុជា មានឋានៈស្មើអនុរដ្ឋលេខាធិការ សំរាប់អាណត្តិទី ៤ ៤១៦៦

២៤-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤១៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម.អស់លោក និង លោកស្រី ចំនួន ១៦ រូប ៤១៦៧

២៥-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤១៥ ស្តីពី ការតែងតាំងឯកឧត្តម **ឯម ប៊ុនធឿន** ជា អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និង ឧតុនិយម ជំនួស ឯកឧត្តម **តែ ឪគីម** ដែលបានទទួលមរណភាព ៤១៦៨

២៦-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤២០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះឯកឧត្តម.អស់លោក និង លោកស្រី ចំនួន ២១ រូប ៤១៦៩

២៦-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤២១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះឯកឧត្តម **ឡោត ហ៊ួរ** និង លោកជំទាវឧកញ៉ា **ឆោម សោភ័ណ្ឌី** ៤១៧០

២៦-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤២២ ស្តីពី ការតែងតាំងអស់លោក និង លោកស្រី ចំនួន ០៣ រូប ជា ឧកញ៉ា ៤១៧១

២៧-៥-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៥១០/៤៣៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និង អស់លោក ចំនួន ១៤ រូប ៤១៧២

## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

២៦-៥-២០១០ -អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៤១៧៣
២៨-៥-២០១០ -អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្តីពី ការកំណត់ទិវាជាតិលើកកម្ពស់អនាម័យជនបទ ៤១៧៥
២៥-៥-២០១០ -អនុក្រឹត្យលេខ ៥៦៨ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៤១៧៧
២៥-៥-២០១០ -អនុក្រឹត្យលេខ ៥៦៩ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៤១៧៩
២៥-៥-២០១០ -អនុក្រឹត្យលេខ ៥៧០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤១៨០
២៥-៥-២០១០ -អនុក្រឹត្យលេខ ៥៧១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៨១
២៥-៥-២០១០ -អនុក្រឹត្យលេខ ៥៧២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤១៨២
២៦-៥-២០១០ -អនុក្រឹត្យលេខ ៥៧៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៨៤
២៦-៥-២០១០ -អនុក្រឹត្យលេខ ៥៧៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤១៨៨
២៧-៥-២០១០ -អនុក្រឹត្យលេខ ៥៧៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៩០
២៧-៥-២០១០ -អនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤១៩១
២៧-៥-២០១០ -អនុក្រឹត្យលេខ ៥៧៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ត្រីវឌ្ឍនា ៤១៩៣
២៧-៥-២០១០ -អនុក្រឹត្យលេខ ៥៧៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៤១៩៥
២៧-៥-២០១០ -អនុក្រឹត្យលេខ ៥៧៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៤១៩៨
២៧-៥-២០១០ -អនុក្រឹត្យលេខ ៥៨០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៤១៩៩

### ២_សេចក្តីសម្រេច

២៨-៥-២០១០ -សេចក្តីសម្រេចលេខ ២៦ សសរ ស្តីពី ការបង្កើតគណៈកម្មការចម្រុះថ្នាក់ជាតិចុះពិនិត្យជាក់ស្តែង ដើម្បីកំណត់តំបន់ ៣ នៃបឹងទន្លេសាប និង ការរំលាយចោលការកែសម្រួលបច្ចេកទេស បណ្តាអាងទឹកដែលបានសាងសង់ឡើងនៅក្នុងតំបន់បឹងទន្លេសាប ៤២០០

## III_ការងារបណ្តាក្រសួង

### ទីស្តីការក្រសួងមន្ត្រីក្រសួងពាណិជ្ជកម្ម

២៤-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០០៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្រូវខ្មែរ លីមីធីត** ៤២០២
២៤-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០១០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយ ថ័ន** ៤២០៤

២៤-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០២០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូតា អេស៊ា អ៊ិនវេសមេន អ៊ីមផត អិចផត** ៤២០៦

២៤-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០២១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ី-គ្រីនធីច (ខេមបូឌា)** ៤២០៨

២៤-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០២៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ានី លក្ខិណា** ៤២១០

២៤-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០២៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូ អ៊ី ឌីវេឡុបមេន** ៤២១២

២៧-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០៣៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ & អិល អេនជីនារីង** ៤២១៤

២៧-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០៣៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ុណ្ណា ប៊ីហ្សនេស សេនធ័រ** ៤២១៦

២៧-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០៤៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្តាតធើរ ស៊ីល្វសិន** ៤២១៨

២៧-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ូរ ស៊ីឧខ្វូន អ៊ិនវេសមេន** ៤២២០

២៧-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០៤៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច.អិន.ខេ ស៊ីឃ្យូរីធី ខូ អិលធីឌី** ៤២២២

២៨-៧-២០០៩ -លិខិតបញ្ជាក់លេខ ៣០៥៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិច ត្រេដ ឌីវេឡុបមេន** ៤២២៤

# ព្រះរាជក្រម

នស/រកម/០៥១០/០០៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ក្រសួងព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL ·

2/12

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និង សិទ្ធិប្រើប្រាស់និងអាស្រ័យផលលើចំណែករួមនៃអគារសហកម្មសិទ្ធិដល់ជនបរទេស ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងដូចតទៅ :

- កំណត់អំពីគោលការណ៍ទូទៅ សិទ្ធិ និង កាតព្វកិច្ចទាំងឡាយសម្រាប់ជនបរទេសដែលមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និង សិទ្ធិផ្សេងទៀតដែលមានទំនាក់ទំនងនឹងចំណែករួម និង កំណត់អំពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិទាំងនោះ
- បង្កលក្ខណៈងាយស្រួលដល់ជនបរទេស ក្នុងការយកទុនមកវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ជួយសម្រួលដល់ធុរកិច្ចរបស់វិនិយោគិនលើវិស័យសំណង់ ព្រមទាំងឆ្លើយតបទៅនឹងការកើនឡើងនៃទីផ្សារអចលនវត្ថុនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះជនបរទេស និង ពលរដ្ឋខ្មែរដែលមានកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យស័ព្ទដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ :

-**ជនបរទេស** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលបរទេសដែលមិនមានសញ្ជាតិខ្មែរ ទោះបីជាបុគ្គលនោះមានសញ្ជាតិ ជំនឿ សាសនា ឬ មានដើមកំណើតពីពូជសាសន៍ណាមួយក៏ដោយ ដោយគ្មានការរើសអើង ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

Ksl

- **ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់** សំដៅដល់ជនបរទេសដែលមានសមត្ថភាពតាមច្បាប់កម្ពុជា និង បានចូលមកព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ ។

- **អគារសហកម្មសិទ្ធិ** សំដៅដល់អគារ ឬ សំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ ។ អគារសហកម្មសិទ្ធិ មានចំណែកខ្លះជាកម្មសិទ្ធិផ្តាច់មុខរបស់សហកម្មសិទ្ធិករនីមួយៗហៅថា “ ចំណែកឯកជន ” និង មានចំណែកខ្លះទៀតសម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ហៅថា “ ចំណែករួម ” ។

- **ចំណែកឯកជន** សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិដែលស្ថិតក្រោមការកាន់កាប់ និង ប្រើប្រាស់ជាឯកជនផ្តាច់មុខ ។

- **សហកម្មសិទ្ធិករលើចំណែកឯកជន** សំដៅដល់បុគ្គលដែលមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន ។

- **ចំណែករួម** សំដៅដល់រាល់ចំណែកនៃអគារសហកម្មសិទ្ធិដែលត្រូវចាត់ជាកម្មវត្ថុសម្រាប់ការប្រើប្រាស់ ឬ ជាប្រយោជន៍នៃសហកម្មសិទ្ធិករទាំងអស់ មានជាអាទិ៍ ដី ទីធ្លា ជណ្តើរ ដំបូល ឧទ្យាននិងសួនច្បារ ផ្លូវ ច្រកចេញចូល ជញ្ជាំងអឌ្ឍសិទ្ធិ ទីកន្លែងនៃសេវាកម្មរួម ។

- **សហកម្មសិទ្ធិពិសេស** សំដៅដល់សិទ្ធិរបស់បុគ្គលច្រើនរូបជាជនបរទេស និង ជាពលរដ្ឋខ្មែរលើអគារសហកម្មសិទ្ធិតែមួយ ដែលក្នុងនោះជនបរទេសនិងពលរដ្ឋខ្មែរមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និង មានសិទ្ធិកម្មសិទ្ធិអវិភាគពិសេសលើចំណែករួមនៃអគារសហកម្មសិទ្ធិ ។

- **សហកម្មសិទ្ធិករពិសេស** សំដៅដល់ជនបរទេសដែលមានសិទ្ធិសហកម្មសិទ្ធិពិសេស ។

- **កម្មសិទ្ធិអវិភាគពិសេស** សំដៅដល់សិទ្ធិរបស់បុគ្គលច្រើនរូបលើចំណែករួមនៃអគារសហកម្មសិទ្ធិ ដែលក្នុងនោះជនបរទេសមានសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួម ហើយពលរដ្ឋខ្មែរមានសិទ្ធិកម្មសិទ្ធិអវិភាគលើចំណែករួម ដោយសារមានកម្មសិទ្ធិលើចំណែកឯកជន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- **ឡូត៍** សំដៅដល់ចំណែកឯកជនដែលភ្ជាប់ទៅនឹងចំណែករួមនៃអគារសហកម្មសិទ្ធិ ។ ឡូត៍នីមួយៗ មានតម្លៃខុសៗគ្នាទៅតាមទំហំតូច ឬ ធំនៃចំណែកឯកជន ហើយការគណនាត្រូវគិតទៅតាមផ្ទៃក្រឡានៃចំណែកឯកជនរបស់សហកម្មសិទ្ធិករនីមួយៗ ។

## ជំពូកទី ២
## គោលការណ៍ទូទៅ

**មាត្រា ៥.-**

ជនបរទេសដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមផ្លូវច្បាប់ មានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ និង សិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួម និងមានកាតព្វកិច្ចគោរពតាមបញ្ញត្តិទាំងឡាយនៃច្បាប់នេះ និង បទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតជាធរមាន ។

**មាត្រា ៦.-**

ជនបរទេសមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ ចាប់ពីជាន់ទី ១ ( មួយ ) ឡើងទៅ ។ ជាន់ផ្ទាល់ដី និង ជាន់ក្រោមដី មិនត្រូវបានអនុញ្ញាតឱ្យជនបរទេសមានសិទ្ធិកម្មសិទ្ធិឡើយ ។

ចំពោះអគារសហកម្មសិទ្ធិមួយកន្លែង សមាមាត្រ និង របៀបគិតគូរនៃចំណែកឯកជនដែលអាចជាកម្មសិទ្ធិរបស់ជនបរទេសត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់កម្មសិទ្ធិនេះ គឺផ្តល់តែលើចំណែកឯកជននៃអគារសហកម្មសិទ្ធិតែប៉ុណ្ណោះ ។ ចំពោះចំណែករួមនៃអគារសហកម្មសិទ្ធិ ត្រូវរក្សាទុកសម្រាប់សហកម្មសិទ្ធិករទាំងអស់ នៅក្នុងអគារសហកម្មសិទ្ធិប្រើប្រាស់ជារួម ។

ក្នុងករណីណាក៏ដោយ ក៏ក្បាលដីដែលអគារសហកម្មសិទ្ធិតាំងនៅ មិនអាចជាកម្មវត្ថុនៃកម្មសិទ្ធិរបស់សហកម្មសិទ្ធិករពិសេសបានឡើយ ។

ជនបរទេស មិនត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលស្ថិតនៅក្នុងចំងាយ ៣០ ( សាមសិប ) គីឡូម៉ែត្រ ពីព្រំដែនគោកឡើយ និង

តំបន់មួយចំនួនទៀត ដែលកំណត់ដោយរាជរដ្ឋាភិបាល លើកលែងតែអគារសហកម្មសិទ្ធិស្ថិតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ទីប្រជុំជនសំខាន់ៗ និង តំបន់ផ្សេងទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិសាងសង់នៅលើដីជួលពីបុគ្គលទី ៣ ជនបរទេសមានសិទ្ធិជួលអចិន្ត្រៃយ៍លើចំណែកឯកជនដូចពលរដ្ឋខ្មែរដែរ ។

## ជំពូកទី ៣
## លទ្ធកម្មនៃសហកម្មសិទ្ធិពិសេស

**មាត្រា ៧.-**

សហកម្មសិទ្ធិពិសេស ត្រូវបានបង្កើត ផ្ទេរ កែប្រែដោយ :

- ការព្រមព្រៀងរវាងភាគីដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត
- សន្តតិកម្ម ។

**មាត្រា ៨.-**

ការផ្ទេរសហកម្មសិទ្ធិពិសេសដោយការព្រមព្រៀងមិនមានអានុភាពទេ ប្រសិនបើមិនបានចុះបញ្ជីដោយយោងតាមបញ្ញត្តិនៃច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ស្តីពីការចុះបញ្ជី ។

**មាត្រា ៩.-**

នៅពេលដែលសហកម្មសិទ្ធិករលើចំណែកឯកជនដែលជាពលរដ្ឋខ្មែរ បានផ្ទេរកម្មសិទ្ធិលើចំណែកឯកជនរបស់ខ្លួនទៅជនបរទេស សហកម្មសិទ្ធិករពិសេសទទួលបានសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និង ទទួលបានត្រឹមតែសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួមតែប៉ុណ្ណោះ ។ ក្នុងករណីនេះ អតីតសហកម្មសិទ្ធិករលើចំណែកឯកជនជាពលរដ្ឋខ្មែរ ត្រូវរក្សាទុកនូវកម្មសិទ្ធិអវិភាគរបស់ខ្លួនលើចំណែករួម ។

ក្នុងករណីដែលសហកម្មសិទ្ធិករលើចំណែកឯកជនជាជនបរទេស បានផ្ទេរចំណែកឯកជនរបស់ខ្លួនមកឱ្យពលរដ្ឋខ្មែរ សហកម្មសិទ្ធិករជាពលរដ្ឋខ្មែរត្រូវទទួលបាននូវសិទ្ធិកម្មសិទ្ធិលើចំណែកឯកជន និង កម្មសិទ្ធិអវិភាគលើចំណែករួម ។

**មាត្រា ១០.-**

សន្តតិជននៃសហកម្មសិទ្ធិករពិសេស ត្រូវទទួលបន្តនូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជនដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

ក្នុងករណីដែលមរតកនៅទំនេរ ដោយគ្មានសន្តតិជនទទួលបន្ត ឬ សន្តតិជនបោះបង់ចោល ឬ មរតកមិនត្រូវបានចាត់ចែងឱ្យទៅជនណាមួយតាមបញ្ញត្តិច្បាប់ មរតកនៅទំនេរនោះ ត្រូវធ្លាក់ទៅជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា ១១.-**

ក្នុងករណីដែលជនបរទេសណា ដែលបានទទួលការផ្ទេរ ឬ ទិញចំណែកឯកជន នៃអគារសហកម្មសិទ្ធិណាមួយ ដោយរំលោភបំពានលើមាត្រា ៦ នៃច្បាប់នេះ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ត្រូវទុកប្រតិបត្តិការនោះជាមោឃៈ ហើយភាគីដែលធ្វើប្រតិបត្តិការជាមួយគ្នាត្រូវធ្វើបដិទានត្រលប់វិញ ។

## ជំពូកទី ៤
## សិទ្ធិ និង កាតព្វកិច្ចរបស់សហកម្មសិទ្ធិករពិសេស
### ផ្នែកទី ១
### សិទ្ធិ និង កាតព្វកិច្ចរបស់សហកម្មសិទ្ធិករពិសេសលើចំណែកឯកជន

**មាត្រា ១២.-**

សហកម្មសិទ្ធិករពិសេសលើចំណែកឯកជន មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងលើចំណែកឯកជន ដែលជាកម្មសិទ្ធិរបស់ខ្លួនបានដោយសេរីក្នុងទំហំដែលច្បាប់ជាធរមាន ។

**មាត្រា ១៣.-**

សហកម្មសិទ្ធិករពិសេសនៃចំណែកឯកជន មិនអាចប្រើប្រាស់ចំណែកឯកជនរបស់ខ្លួនក្នុងគោលបំណងព្យាបាទ បំពាន ឬ រាំងស្ទះដល់ការប្រើប្រាស់ ឬ រំខានដល់ជីវភាពរស់នៅរបស់សហកម្មសិទ្ធិករលើចំណែកឯកជនផ្សេងទៀតឡើយ ។

សហកម្មសិទ្ធិករពិសេសនៃចំណែកឯកជន មិនត្រូវប្រព្រឹត្តអំពើណាដែលនាំឱ្យប៉ះពាល់ដល់ការថែរក្សាអគារសហកម្មសិទ្ធិ ឬ អំពើផ្សេងទៀតដែលផ្ទុយនឹងប្រយោជន៍រួមរបស់សហកម្មសិទ្ធិករលើចំណែកឯកជនទាក់ទងនឹងការគ្រប់គ្រង ឬ ប្រើប្រាស់អគារសហកម្មសិទ្ធិឡើយ ។

**មាត្រា ១៤.-**

សហកម្មសិទ្ធិករពិសេសលើចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានកាតព្វកិច្ច និង បន្ទុកផ្សេងៗដូចសហកម្មសិទ្ធិករខ្មែរដែរ ។ សហកម្មសិទ្ធិករពិសេសត្រូវគោរពរាល់កាតព្វកិច្ច និង/ ឬ បន្ទុកដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងនៃអគារសហកម្មសិទ្ធិ និង/ ឬ ច្បាប់ជាធរមាន ។

## ផ្នែកទី ២

## សិទ្ធិ និង កាតព្វកិច្ចរបស់សហកម្មសិទ្ធិករពិសេសលើចំណែករួម

**មាត្រា ១៥.-**

ចំណែករួមត្រូវស្ថិតនៅក្នុងរបបកម្មសិទ្ធិអវិភាគពិសេស របស់សហកម្មសិទ្ធិករលើចំណែកឯកជនទាំងអស់ ។

សហកម្មសិទ្ធិករពិសេស មានត្រឹមសិទ្ធិប្រើប្រាស់ និង អាស្រ័យផលប៉ុណ្ណោះលើចំណែករួម ។




Ksl

**មាត្រា ១៦.–**

កម្មសិទ្ធិអវិភាគពិសេស និង សិទ្ធិបន្ទាប់បន្សំផ្សេងទៀតដែលទទួលស្គាល់ដោយច្បាប់ មិនអាចជាកម្មវត្ថុនៃការបែងចែក ចាត់ចែង និង បង្ខំឱ្យលក់ដាច់ដោយឡែកពីចំណែកឯកជនបានឡើយ ។

**មាត្រា ១៧.–**

សហកម្មសិទ្ធិករពិសេស ត្រូវចូលរួមការថែទាំចំណែករួម ។ បន្ទុកនៃការថែទាំនេះ ត្រូវចែកគ្នាទៅតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ លើកលែងតែមានការព្រមព្រៀងគ្នាផ្សេងពីនេះ ឬ មានចែងដោយឡែកក្នុងបទបញ្ជាផ្ទៃក្នុង ។

**មាត្រា ១៨.–**

សិទ្ធិប្រើប្រាស់ និង អាស្រ័យផល លើចំណែករួមរាប់បញ្ចូលទាំងដី ដែលអគារសហ-កម្មសិទ្ធិតាំងនៅ ឬ ដីដែលរៀបចំដើម្បីជាទីធ្លាអគារ ដែលត្រូវបានកំណត់ថាជាចំណែករួម គឺជាសិទ្ធិដែលមិនត្រូវបាន បាត់បង់ឡើយ ទោះបីជាអគារ ឬ ចំណែកឯកជននោះត្រូវបាន បាត់បង់ក៏ដោយ ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិទ្រុឌទ្រោម មិនអាចស្នាក់នៅបាន ឬ ទទួលរងមហន្តរាយដោយប្រការណាមួយ ឬ ដោយវិធានការបង្ខំឱ្យរុះរើដោយអាជ្ញាធរមានសមត្ថ-កិច្ចដើម្បីសុវត្ថិភាពរបស់អ្នកស្នាក់នៅ សហកម្មសិទ្ធិករទាំងអស់អាចឯកភាពគ្នា ជួសជុល ឬ សាងសង់ជាថ្មីឡើងវិញ ដោយទទួលបន្ទុកក្នុងការចំណាយតាមសមាមាត្រទៅនឹងតម្លៃនៃឡូតិ៍នីមួយៗ ឬ តាមការព្រមព្រៀងគ្នាកន្លងមក ឬ តាមបទបញ្ជាផ្ទៃក្នុង ។ ការជួសជុល ឬ សាងសង់ឡើងវិញ ត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន ស្តីពីលិខិតអនុញ្ញាតសាងសង់ និង ត្រូវរក្សារចនាសម្ព័ន្ធដើមនៃអគារដដែល លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ ឬ មានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់អគារសហកម្មសិទ្ធិ ។

ក្នុងករណីដែលអគារសហកម្មសិទ្ធិទទួលរងនូវមហន្តរាយទាំងស្រុង ដោយអំពើរបស់មនុស្ស ឬ ដោយប្រធានសក្តិ ហើយសហកម្មសិទ្ធិករសញ្ជាតិខ្មែរ ឯកភាពគ្នាលក់ដីដែល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ksl

អគារសហកម្មសិទ្ធិតាំងនៅ សហកម្មសិទ្ធិករពិសេសមានសិទ្ធិទទួលបាននូវផលប្រយោជន៍ពីសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើចំណែករួម ស្របតាមសមាមាត្រទៅនឹងផ្ទៃក្រឡានៃទំហំចំណែកឯកជនរបស់ខ្លួន ឬ តាមការព្រមព្រៀងគ្នាពីមុនមក ឬ បទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី ៥
## នីតិវិធីនៃការចុះបញ្ជី និង ការចេញវិញ្ញាបនបត្រ

**មាត្រា ១៩.-**

បទប្បញ្ញត្តិនៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀតដែលទាក់ទងនឹងយន្តការនីតិវិធីនៃការចុះបញ្ជី និង ការចេញវិញ្ញាបនបត្រ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះនីតិវិធីនៃការចុះបញ្ជី និង ការចេញវិញ្ញាបនបត្រសម្រាប់សហកម្មសិទ្ធិពិសេសនៃអគារសហកម្មសិទ្ធិ ។

គំរូវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជនជាសហកម្មសិទ្ធិករពិសេស និង កំណត់ត្រាបញ្ជាក់ផ្សេងៗអំពីសិទ្ធិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ២០.-**

សហកម្មសិទ្ធិករពិសេសដែលធ្វើឱ្យប៉ះពាល់ចំណែករួមនៃអគារ ឬ ដីដោយបានកែប្រែដើម្បីការប្រើប្រាស់ជាឯកជន ឬ សម្រាប់លក់ នឹងត្រូវបង្ខំឱ្យរៀបចំដូចសភាពដើមវិញ ។ សហកម្មសិទ្ធិករនោះត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា ២៥៧ នៃច្បាប់ភូមិបាល ។

សហកម្មសិទ្ធិករពិសេសដែលមិនព្រមចូលរួមទទួលបន្ទុកថែទាំចំណែករួម ឬ មិនបានគោរពតាមលក្ខខណ្ឌនៃសណ្តាប់ធ្នាប់សាធារណៈ ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា ២៥៨ នៃច្បាប់ភូមិបាល ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ព្រះបរមរាជវាំង

kol

**មាត្រា ២១.-**

ការរំលោភធ្វើឡើងដោយមន្ត្រីសុរិយោដី ពាក់ព័ន្ធនឹងការចុះបញ្ជី ឬ ការចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដល់សហកម្មសិទ្ធិករពិសេស ដោយបំពានលើបញ្ញត្តិទាំងឡាយនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៦៤ នៃច្បាប់ភូមិបាល ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ២២.-**

ជនបរទេសណាដែលបានទទួលទិញ ឬទទួលការផ្ទេរចំណែកឯកជននៃអគារសហកម្មសិទ្ធិមុនច្បាប់នេះចូលជាធរមាន ហើយមិនស្របនឹងបញ្ញត្តិទាំងឡាយដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ ត្រូវបានអនុញ្ញាតឱ្យធ្វើការដោះស្រាយដើម្បីឱ្យស្របតាមច្បាប់នេះឡើងវិញក្នុងរយៈពេល ០២ ( ពីរ )ឆ្នាំ ។

ក្នុងករណីដែលមិនគោរពតាមកថាខណ្ឌទី ១ នោះ អាជ្ញាធរមានសមត្ថកិច្ចត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច ដើម្បីឱ្យលក់ចំណែកឯកជននៃអគារសហកម្មសិទ្ធិនោះដោយបង្ខំ ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ២៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៤.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣/ល.១០០៥.៤១៥ **នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ហត្ថលេខា**

**អ៊ឹម ឈុនលឹម**

**លេខ: ៣៧៧ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ ឧសភា ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

12/12

# ព្រះរាជក្រឹត្យ

នស/រកត/០៥១០/៤១១

**យើង**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបន្ថយរយៈពេលទទួលរងទោសពីមួយជីវិតមកត្រឹមម្ភៃឆ្នាំឱ្យទណ្ឌិតចំនួន ២ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោម ÷

១-ទណ្ឌិតឈ្មោះ **ខាន់ គឹមស្រ៊ុន** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-៦-១៩៩៨ ពីបទចាប់មនុស្សជំរិតយកប្រាក់ បណ្តាលឱ្យជនរងគ្រោះបាត់បង់ជីវិត និងចរាចរក្រដាសប្រាក់ក្លែងក្លាយ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់មួយជីវិត តាមអំណាចសាលដីកាលេខ ០១ "ឃ" ចុះថ្ងៃទី ២៨-០១-២០០៥ របស់សាលាឧទ្ធរណ៍ ។

២-ទណ្ឌិតឈ្មោះ **ឈាង ចណ្ណៈ** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-៦-១៩៩៨ ពីបទចាប់មនុស្សជំរិតយកប្រាក់ បណ្តាលឱ្យជនរងគ្រោះបាត់បង់ជីវិត និងចរាចរក្រដាសប្រាក់ក្លែងក្លាយ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់មួយជីវិត តាមអំណាចសាលដីកាលេខ ០១ "ឃ" ចុះថ្ងៃទី ២៨-០១-២០០៥ របស់សាលាឧទ្ធរណ៍ ។

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL

**មាត្រា ២ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ១២ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោម ÷

១-ទណ្ឌិតឈ្មោះ **ហែម លី** ភេទស្រី អាយុ ៤៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-១១-២០០៤ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤ ចុះថ្ងៃទី ២៩-៤-២០០៥ របស់សាលាដំបូងខេត្តរតនគិរី ។

២-ទណ្ឌិតឈ្មោះ **កែវ ពិសិដ្ឋ** ហៅ ធី ហៅ ក្រូច សំណាង ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១២-០២-២០០១ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០២ ចុះថ្ងៃទី ០៧-៨-២០០១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

៣-ទណ្ឌិតឈ្មោះ **មុំ សុផាន់** ហៅ អ៊ា ណារ៉េន ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-៣-២០០៣ ពីបទ មនុស្សឃាតដោយចេតនា និងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៧០ ចុះថ្ងៃទី ០៣-៨-២០០៩ របស់តុលាការកំពូល ។

៤-ទណ្ឌិតឈ្មោះ **អឿម សារុន** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-១២-២០០២ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលដីកាលេខ ០៤ "ជ" ចុះថ្ងៃទី ២៥-០១-២០០៥ របស់សាលាឧទ្ធរណ៍ ។

៥-ទណ្ឌិតឈ្មោះ **ស៊ុំ សុខមាឃ** ហៅ ប៉ូឡូ ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-១២-១៩៩៩ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៩ ចុះថ្ងៃទី ១៨-៣-២០០៩ របស់តុលាការកំពូល ។

៦-ទណ្ឌិតឈ្មោះ **ញ៉ិល ញ៉ារណា** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-៣-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៥ ចុះថ្ងៃទី ០៨-៧-១៩៩៩ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៧-ទណ្ឌិតឈ្មោះ **ជិន សាលួន** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៧-១៩៩៧ ពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៩ ចុះថ្ងៃទី ០៣-១០-១៩៩៧ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៨-ទណ្ឌិតឈ្មោះ **សុត ផាត** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣១-១០-១៩៩៨ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី ១១-០២-១៩៩៩ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៩-ទណ្ឌិតឈ្មោះ **ប៊ុន ហ៊ាង** ភេទស្រី អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៥-២០០៣ ពីបទសមគំនិតសម្លាប់មនុស្សដោយគិតទុកជាមុន និងកាន់កាប់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០០ ចុះថ្ងៃទី ០៤-១១-២០០៣ របស់សាលាដំបូងខេត្តកំពត ។

១០-ទណ្ឌិតឈ្មោះ **គង់ សុវណ្ណឌី** ភេទប្រុស អាយុ ៤៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-០២-១៩៩៧ ពីបទ [illegible] ប៉ុនប៉ងសម្លាប់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ [illegible] ឆ្នាំ តាមអំណាចសាលក្រមលេខ ៥១ ចុះថ្ងៃទី ២៣-៩-១៩៩៧ របស់សាលាដំបូងខេត្តកំពត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

2/234

១១-ទណ្ឌិតឈ្មោះ **សេង សំណាង** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-០២-១៩៩៧ ពីបទ ប្លន់សម្លាប់ ប៉ុនប៉ងសម្លាប់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥១ ចុះថ្ងៃទី ២៣-៩-១៩៩៧ របស់សាលាដំបូងខេត្តកំពត ។

១២-ទណ្ឌិតឈ្មោះ **ខៀវ ពៅ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៣-០២-១៩៩៧ ពីបទ ប្លន់សម្លាប់ ប៉ុនប៉ងសម្លាប់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥១ ចុះថ្ងៃទី ២៣-៩-១៩៩៧ របស់សាលាដំបូងខេត្តកំពត ។

**មាត្រា ៣ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ២៦ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោម ÷

១-ទណ្ឌិតឈ្មោះ **ប្ញ ផល** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-១២-២០០០ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៤ ចុះថ្ងៃទី ១២-៧-២០០១ របស់សាលាដំបូងខេត្តរតនគិរី ។

២-ទណ្ឌិតឈ្មោះ **ឡុង សុផល** ហៅ ជា ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៣-២០០១ ពីបទ ប្លន់ប្រដាប់អាវុធ សម្លាប់មនុស្ស និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១១៥ ចុះថ្ងៃទី ២៥-៩-២០០១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

៣-ទណ្ឌិតឈ្មោះ **អ៊ុន តុប** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-០១-២០០៤ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៧ ចុះថ្ងៃទី ២៤-៥-២០០៤ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

៤-ទណ្ឌិតឈ្មោះ **សៅ ចំរើន** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៩-២០០២ ពីបទ ញុះញង់សម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣៨ ចុះថ្ងៃទី ០៤-១២-២០០២ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ។

៥-ទណ្ឌិតឈ្មោះ **ម៉ៅ ឌី** ភេទស្រី អាយុ ៥២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-០២-២០០៦ ពីបទ អំពើជួញដូរមនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧១ "ក" ចុះថ្ងៃទី ១១-៧-២០០៦ របស់សាលាដំបូងខេត្តកោះកុង ។

៦-ទណ្ឌិតឈ្មោះ **អ៊ុំ ខួច** ភេទស្រី អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៤-២០០៥ ពីបទ អំពើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧១ ចុះថ្ងៃទី ១៥-៨-២០០៥ របស់សាលាដំបូងខេត្តកោះកុង ។

៧-ទណ្ឌិតឈ្មោះ **ជេត តក់** ភេទប្រុស អាយុ ៤៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-០២-២០០២ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៧៣ "ជ" ចុះថ្ងៃទី ២០-៧-២០០៦ របស់សាលាឧទ្ធរណ៍ ។

៨-ទណ្ឌិតឈ្មោះ **ម៉ុន រដ្ឋា** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-០៣-២០០៤ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៤ "ខ" ចុះថ្ងៃទី ២៤-១១-២០០៤ របស់សាលាដំបូងខេត្តតាកែវ ។

3/23

៩-ទណ្ឌិតឈ្មោះ **ញើ សារឿន** ភេទស្រី អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៩-២០០១ ពីបទ ពង្រត់មនុស្សយកទៅលក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាល ដីកាលេខ ៣៤ "ជ" ចុះថ្ងៃទី ២៩-៦-២០០៥ របស់សាលាឧទ្ធរណ៍ ។

១០-ទណ្ឌិតឈ្មោះ **សុខ ចន្ថា** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-១១-២០០២ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រម លេខ ៤៣ ចុះថ្ងៃទី ០៦-៣-២០០៣ របស់សាលាដំបូងខេត្តព្រះសីហនុ ។

១១-ទណ្ឌិតឈ្មោះ **ម៉ក ឆាច** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-៦-២០០០ ពីបទ ប្លន់ និងធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាច សាលក្រមលេខ ២៦ ចុះថ្ងៃទី ២៦-៨-១៩៩៧ របស់សាលាដំបូងខេត្តព្រះសីហនុ ។

១២-ទណ្ឌិតឈ្មោះ **IGBOELI CHUKWUVEM ANTHORNY** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-០១-២០០៥ ពីបទ ជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ១០១ ចុះថ្ងៃទី ១១-១១-២០០៩ របស់តុលាការកំពូល ។

១៣-ទណ្ឌិតឈ្មោះ **សំ ឧុឌ្ឍី** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-១០-២០០៥ ពីបទ មនុស្សឃាត ដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ ៣២ "ខ" ចុះថ្ងៃទី ១២-៧-២០០៦ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៤-ទណ្ឌិតឈ្មោះ **សំ សុខឌី** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-១០-២០០៥ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាច សាលក្រមលេខ ៣២ "ខ" ចុះថ្ងៃទី ១២-៧-២០០៦ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៥-ទណ្ឌិតឈ្មោះ **ម៉ៅ ដារ៉ា** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៥-២០០៥ ពីបទ ទិញលក់ គ្រឿងញៀនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាម អំណាចសាលក្រមលេខ ៣០ "គ" ចុះថ្ងៃទី ១៩-៩-២០០៥ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៦-ទណ្ឌិតឈ្មោះ **សុខ រ៉ាន់** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៣-៤-២០០៥ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ ៤២ "យ" ចុះថ្ងៃទី ២១-១០-២០០៥ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៧-ទណ្ឌិតឈ្មោះ **ហៀម ហ៊ន់** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-៤-២០០០ ពីបទ ឃាតកម្ម គិតទុកជាមុន និងប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាច សាលក្រមលេខ ១២៧ ចុះថ្ងៃទី ២០-១០-២០០០ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៨-ទណ្ឌិតឈ្មោះ **សន ខាន់** ភេទប្រុស អាយុ ៤៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-៩-២០០៣ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាច សាលក្រមលេខ ៦៤ ចុះថ្ងៃទី ៣០-៣-២០០៤ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៩-ទណ្ឌិតឈ្មោះ **រាជ្យ រ៉េម** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៨-២០០៤ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ ០៤ "ក" ចុះថ្ងៃទី ១៧-០១-២០០៥ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL
5/23

២០-ទណ្ឌិតឈ្មោះ **ព្រំច ចោយ** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-១២-២០០២ ពីបទ អំពើភេរវកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ ចុះថ្ងៃទី ១១-៦-២០០៣ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

២១-ទណ្ឌិតឈ្មោះ **សាំង សាមុត** ភេទប្រុស អាយុ ៤១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១០-៩-២០០២ ពីបទ សម្លាប់មនុស្សដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ ៤១ ចុះថ្ងៃទី ៣០-៥-២០០៣ របស់សាលាដំបូងខេត្តកំពត ។

២២-ទណ្ឌិតឈ្មោះ **ហែម ណារា** ភេទស្រី អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៧-២០០៤ ពីបទ សម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាច សាលក្រមលេខ ១៧ ចុះថ្ងៃទី ០១-០២-២០០៥ របស់សាលាដំបូងខេត្តកំពត ។

២៣-ទណ្ឌិតឈ្មោះ **ប៉ុល សាលី** ហៅ ថៃ ភេទស្រី អាយុ ៥៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-១២-២០០២ ពីបទ ជួញដូរមនុស្ស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកា លេខ ២២ "ជ" ចុះថ្ងៃទី ១៦-០១-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៤-ទណ្ឌិតឈ្មោះ **លុយ គៀរ** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៦-២០០១ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលដីកា លេខ ១០១ "ង" ចុះថ្ងៃទី ១២-៦-២០០៧ របស់សាលាឧទ្ធរណ៍ ។

២៥-ទណ្ឌិតឈ្មោះ **ម៉ុន ហ៊ុល** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៤-៩-២០០៤ ពីបទ សមគំនិតក្នុងអំពើប៉ុនប៉ងធ្វើមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាម អំណាចសាលដីកាលេខ ១០៥ "ខ" ចុះថ្ងៃទី ២៣-៧-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៦-ទណ្ឌិតឈ្មោះ **ខុន សុខណេង** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-១១-២០០៥ ពីបទ មនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦១ ចុះថ្ងៃទី ០៥-៣-២០០៦ របស់សាលាដំបូងខេត្តក្រចេះ ។

**មាត្រា ៤** : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ១៤១ នាក់ ដែលបានខិតខំកែប្រែខ្លួន បានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោម ÷

១-ទណ្ឌិតឈ្មោះ **រលៀត ចាត់** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-១២-២០០៦ ពីបទ ប្លន់ម៉ូតូ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ៣០-៨-២០០៧ របស់សាលាដំបូងខេត្តរតនគិរី ។

២-ទណ្ឌិតឈ្មោះ **ភ្នំ ថ៊ុក** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-១២-២០០៦ ពីបទ ប្លន់ម៉ូតូ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ៣០-៨-២០០៧ របស់សាលាដំបូងខេត្តរតនគិរី ។

៣-ទណ្ឌិតឈ្មោះ **ស៊ុំ ចិត្រា** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៥-២០០៥ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "ន" ចុះថ្ងៃទី [illegible]-៨-២០០៧ របស់សាលាដំបូងខេត្តកណ្តាល ។

៤-ទណ្ឌិតឈ្មោះ **ស៊ុំ យ៉ា** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-១៥-២០០៥ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "ន" ចុះថ្ងៃទី ៣០-៨-២០០៧ របស់សាលាដំបូងខេត្តកណ្តាល ។

៥-ទណ្ឌិតឈ្មោះ **ធី ចាន់ធឿន** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-០១-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២០ "ច" ចុះថ្ងៃទី ២៩-៣-២០០៧ របស់សាលាដំបូងខេត្តកណ្តាល ។

៦-ទណ្ឌិតឈ្មោះ **ឈឹម ទិរះ** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-១២-២០០៤ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៩ "ជ" ចុះថ្ងៃទី ០៥-៧-២០០៦ របស់សាលាដំបូងខេត្តកណ្តាល ។

៧-ទណ្ឌិតឈ្មោះ **ទ្រី ចូច** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៣-៦-២០០៥ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៤ "រ" ចុះថ្ងៃទី ០២-១១-២០០៥ របស់សាលាដំបូងខេត្តកណ្តាល ។

៨-ទណ្ឌិតឈ្មោះ **ឆាន ឡី** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-១១-២០០៦ ពីបទ ប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ "ផ" ចុះថ្ងៃទី ០៨-០១-២០០៨ របស់សាលាដំបូងខេត្តកណ្តាល ។

៩-ទណ្ឌិតឈ្មោះ **ម៉េង ធឿន** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៥-២០០៨ ពីបទ ចោរកម្ម (លួចខោអាវ) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ "លម" ចុះថ្ងៃទី ៣១-៣-២០០៩ របស់សាលាដំបូងខេត្តកណ្តាល ។

១០-ទណ្ឌិតឈ្មោះ **អឿ ទ្រី** ភេទប្រុស អាយុ ៥១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣១-១២-២០០៥ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៤ "រ" ចុះថ្ងៃទី ២៣-០២-២០០៧ របស់សាលាដំបូងខេត្តកណ្តាល ។

១១-ទណ្ឌិតឈ្មោះ **រុំ ចន្ថា** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៦-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ "ឡ" ចុះថ្ងៃទី ១៩-៨-២០០៨ របស់សាលាដំបូងខេត្តកណ្តាល ។

១២-ទណ្ឌិតឈ្មោះ **ឌិត សុខហេង** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-០១-២០០៦ ពីបទ បង្ករបួសស្នាមដោយចេតនា និងបង្ខាំងមនុស្សដោយខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ "ព" ចុះថ្ងៃទី ០៨-១១-២០០៥ របស់សាលាដំបូងខេត្តកណ្តាល ។

១៣-ទណ្ឌិតឈ្មោះ **សេក ចាន់រស្មី** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-១០-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ "ឌ" ចុះថ្ងៃទី ២៦-៧-២០០៧ របស់សាលាដំបូងខេត្តកណ្តាល ។

១៤-ទណ្ឌិតឈ្មោះ **យាន ឈី** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-០១-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ "ឌ" ចុះថ្ងៃទី ១៥-០២-២០០៨ របស់សាលាដំបូងខេត្តកណ្តាល ។

១៥-ទណ្ឌិតឈ្មោះ **ម៉ិល ឆា** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២០-១២-២០០៤ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ "ផ" ចុះថ្ងៃទី ០៥-៧-២០០៦ របស់សាលាដំបូងខេត្តកណ្តាល ។

១៦-ទណ្ឌិតឈ្មោះ **ថុំង សុភាព** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-១១-២០០៥ ពីបទប៉ុនប៉ងធ្វើមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលដីកាលេខ ៦៥ ចុះថ្ងៃទី ២១-១១-២០០១ របស់តុលាការកំពូល ។

១៧-ទណ្ឌិតឈ្មោះ **កើត អឿន** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-១១-២០០៦ ពីបទប្លន់ (លួចមានគ្នាច្រើន). ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលដីកាលេខ ១៤៣ "ជ" ចុះថ្ងៃទី ០១-៩-២០០៩ របស់សាលាឧទ្ធរណ៍ ។

១៨-ទណ្ឌិតឈ្មោះ **ស៊ីម ពីសី** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៩-៤-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២៦ "ឈ" ចុះថ្ងៃទី ០៣-៨-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

១៩-ទណ្ឌិតឈ្មោះ **ចក់ ឡុញ** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-៨-២០០៦ ពីបទប្លន់ ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ "ក" ចុះថ្ងៃទី ៣០-០១-២០០៧ របស់សាលាដំបូងខេត្តកោះកុង ។

២០-ទណ្ឌិតឈ្មោះ **មួន ដាវី** ភេទស្រី អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៦-២០០៦ ពីបទសមគំនិតក្នុងអំពើប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ១០៩ ចុះថ្ងៃទី ០១-១២-២០០៦ របស់សាលាដំបូងខេត្តកោះកុង ។

២១-ទណ្ឌិតឈ្មោះ **ម៉ុយ ម៉ាង** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១០-២០០៥ ពីបទប្លន់ប្រដាប់អាវុធ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១៦ ចុះថ្ងៃទី ១៣-៣-២០០៦ របស់សាលាដំបូងខេត្តតាកែវ ។

២២-ទណ្ឌិតឈ្មោះ **ជី ភាព** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-១០-២០០៤ ពីបទប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ "ខ" ចុះថ្ងៃទី ១១-៥-២០០៥ របស់សាលាដំបូងខេត្តតាកែវ ។

២៣-ទណ្ឌិតឈ្មោះ **ឌុច ម៉ៅ** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៧-២០០៦ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៣ ចុះថ្ងៃទី ២៣-១១-២០០៦ របស់សាលាដំបូងខេត្តព្រះសីហនុ ។

២៤-ទណ្ឌិតឈ្មោះ **ជ័ រតនា** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៦-២០០៧ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៣ "ក" ចុះថ្ងៃទី ០២-១០-២០០៧ របស់សាលាដំបូងខេត្តព្រះសីហនុ។

២៥-ទណ្ឌិតឈ្មោះ **ឆេង សាម៉ុង** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៦-២០០៧ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៣ "ក" ចុះថ្ងៃទី ០២-១០-២០០៧ របស់សាលាដំបូងខេត្តព្រះសីហនុ ។

២៦-ទណ្ឌិតឈ្មោះ **តិច ហ៊ន** ភេទស្រី អាយុ ៤៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-៦-២០០៧ ពីបទសញ្ចោរកម្ម ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលដីកាលេខ ១០៣ "ស" ចុះថ្ងៃទី ១៤-៩-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៧-ទណ្ឌិតឈ្មោះ **អឿន ចន្ធី** ភេទស្រី អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-០១-២០០៨ ពីបទសញ្ចោរកម្ម ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលដីកាលេខ ៨៦ "៣" ចុះថ្ងៃទី ០២-៩-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៨-ទណ្ឌិតឈ្មោះ **យ៉ុម ផល្លា** ភេទស្រី អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-០១-២០០៨ ពីបទសញ្ចោរកម្ម ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលដីកាលេខ ៨៦ "៣" ចុះថ្ងៃទី ០២-៩-២០០៩ របស់សាលាឧទ្ធរណ៍ ។

២៩-ទណ្ឌិតឈ្មោះ **សំ សម្បត្តិ** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-១២-២០០៨ ពីបទប្លន់ (គាស់ផ្ទះ) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៣៥ "កប៥" ចុះថ្ងៃទី ២២-៦-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣០-ទណ្ឌិតឈ្មោះ **ហេង បញ្ញា** ភេទប្រុស អាយុ ១៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-៣-២០០៩ ពីបទប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៧ "ក្រ៣" ចុះថ្ងៃទី ១០-៨-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣១-ទណ្ឌិតឈ្មោះ **សឿ វ៉ាន់ឌី** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-០២-២០០៨ ពីបទប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៧ "ក្រ២" ចុះថ្ងៃទី ១៨-៨-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣២-ទណ្ឌិតឈ្មោះ **សឿង ដារ៉ូ** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-០២-២០០៩ ពីបទប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៦២ "កបIV" ចុះថ្ងៃទី ២៣-៧-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣៣-ទណ្ឌិតឈ្មោះ **អេល មូសា** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-០២-២០០៩ ពីបទប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៧៣ "កបIV" ចុះថ្ងៃទី ១១-៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣៤-ទណ្ឌិតឈ្មោះ **តាំង សុខទ្រី** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-៦-២០០៨ ពីបទប្លន់ (ឆក់ខ្សែក) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២៦ "កប៣" ចុះថ្ងៃទី ១៧-១២-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣៥-ទណ្ឌិតឈ្មោះ **វ៉ាន់ រដ្ឋា** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-១០-២០០៨ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៥០ "ក្រ២" ចុះថ្ងៃទី ០៦-៥-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣៦-ទណ្ឌិតឈ្មោះ **សេង សុគន្ធា** ភេទប្រុស អាយុ ១៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-១០-២០០៨ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ១១២ "ក្រ២" ចុះថ្ងៃទី ២៨-៧-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣៧-ទណ្ឌិតឈ្មោះ **នួន ច័ន្ទមង្គល** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-០១-២០០៩ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រម លេខ ៧១ "ក្រ២" ចុះថ្ងៃទី ០៨-៦-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣៨-ទណ្ឌិតឈ្មោះ **លី ជីវ័ន្ត** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-៣-២០០៩ ពីបទ ប្លន់ (ឆក់ថង់ប្រាក់) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រម លេខ ១២០ "ក្រ១" ចុះថ្ងៃទី ១៦-៩-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៣៩-ទណ្ឌិតឈ្មោះ **ជូ សុជាតិ** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-១២-២០០៨ ពីបទ ប្លន់ (ឆក់ទូរស័ព្ទ) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រម លេខ ៦៨ "ក្រ១" ចុះថ្ងៃទី ០៩-៦-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤០-ទណ្ឌិតឈ្មោះ **រិទ្ធ រដ្ឋា** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-០២-២០០៧ ពីបទ ប្លន់ និងកាន់កាប់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រម លេខ ៥៩ "ឆ" ចុះថ្ងៃទី ៣១-៥-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤១-ទណ្ឌិតឈ្មោះ **អ៊ឹម សុខពិសិដ្ឋ** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-០២-២០០៧ ពីបទ ប្លន់ និងកាន់កាប់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាច សាលក្រមលេខ ៥៩ "ឆ" ចុះថ្ងៃទី ៣១-៥-២០០៧ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤២-ទណ្ឌិតឈ្មោះ **ទ៉ាន់ ប៊ូរី** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៨-១២-២០០៨ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាច សាលក្រមលេខ ៥៣ "កប៥" ចុះថ្ងៃទី ៣០-៧-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

៤៣-ទណ្ឌិតឈ្មោះ **ត្រី ដារតន៍** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-១២-២០០៨ ពីបទ ប្លន់ និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ៦ ខែ តាមអំណាច សាលក្រមលេខ ១១៣ "ក្រ១" ចុះថ្ងៃទី ២៧-៨-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៤-ទណ្ឌិតឈ្មោះ **គង់ ច័ន្ទមករា** ភេទប្រុស អាយុ ១៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៣-២០០៩ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៨ "កប៥" ចុះថ្ងៃទី ២៤-៨-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៥-ទណ្ឌិតឈ្មោះ **វី សុខកែន** ហៅ វី ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-៣-២០០៨ ពីបទ ប្លន់ (គាស់ផ្ទះយកសម្ភារៈ) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ១១១ "កប៣" ចុះថ្ងៃទី ២០-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៦-ទណ្ឌិតឈ្មោះ **គុណ សុដល្លា** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១១-៣-២០០៨ ពីបទ ប្លន់ (គាស់ផ្ទះយកសម្ភារៈ) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ១១១ "កប៣" ចុះថ្ងៃទី ២០-១១-២០០៨ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៧-ទណ្ឌិតឈ្មោះ **ជា សុផល** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខនៅថ្ងៃទី ២២-៥-២០០៦ ពីបទ ប្លន់ ([illegible]) ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣១ "ឋ" [illegible]ថ្ងៃទី ១[illegible]-១០-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៨-ទណ្ឌិតឈ្មោះ **នៅ តារិទ្ធ** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៨-២០០៦ ពីបទ ប្លន់ (ឆក់កាបូប) ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣១ "ឋ" ចុះថ្ងៃទី ១៦-១០-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៤៩-ទណ្ឌិតឈ្មោះ **ភាន់ះ សារីគី** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៦-២០០៧ ពីបទ ប្លន់គាស់ទំលុះទំលាយ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ១១ "កបIV" ចុះថ្ងៃទី ១២-៣-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥០-ទណ្ឌិតឈ្មោះ **ម៉ុន រហ្វី** ហៅ នាង សាហ្វី ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២១-៨-២០០៧ ពីបទ ប្លន់ គាស់ទំលុះទំលាយ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ១១ "កបIV" ចុះថ្ងៃទី ១២-៣-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥១-ទណ្ឌិតឈ្មោះ **ម៉ុត សាលីម** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-១២-២០០៦ ពីបទ ប្លន់គាស់ទម្លុះទម្លាយ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ១១ "កបIV" ចុះថ្ងៃទី ១២-៣-២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ។

៥២-ទណ្ឌិតឈ្មោះ **ទ៉ែ លឿ** ហៅ ង៉ោ ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៦-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២០៤ "ដ" ចុះថ្ងៃទី ០៦-១២-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ។

